ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ


# សេចក្តីជូនដំណឹង
# ស្តីពី
# ពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០២៤

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់ក្រសួង ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារ សិស្ស-និស្សិត និងសាធារណជនជ្រាបថា ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា រាជធានីភ្នំពេញ សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា មូលនិធិអភិវឌ្ឍន៍ជំនាញ និងក្រោមការគាំទ្រដោយអង្គការអន្តរជាតិខាងការងារ ដើម្បីរៀបចំ **«ពិព័រណ៍ការងារ និងផលិតភាពជាតិឆ្នាំ២០២៤»** រយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃទី២៦-២៧ ខែតុលា ឆ្នាំ២០២៤ នៅមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ព្រមទាំងរៀបចំឱ្យមានការដាក់ពាក្យតាមប្រព័ន្ធអនឡាញតាមរយៈគេហទំព័រ www.careerfair.nea.gov.kh។

ព្រឹត្តិការណ៍ការងារដ៏ធំជាងគេប្រចាំឆ្នាំ២០២៤ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បី៖

- បង្កើតជាវេទិកាដ៏ធំរវាង អ្នកស្វែងរកការងារ និយោជក និងអ្នកផ្តល់ការអប់រំបណ្តុះបណ្តាល ដើម្បីដាក់ពាក្យស្វែងរកការងារ ជ្រើសរើសបុគ្គលិក ផ្សព្វផ្សាយព័ត៌មានឱកាសការងារ វគ្គអប់រំបណ្តុះបណ្តាល និងប្រឹក្សាយោបល់អាជីព ការងារ និងវិជ្ជាជីវៈ
- បង្កើនការយល់ដឹង បណ្តុះផ្នត់គំនិត និងផ្សព្វផ្សាយពីការបង្កើនផលិតភាពការងារ តាមរយៈសិក្ខាសាលាដែលចូលរួមចែករំលែកដោយវាគ្មិនដែលមានបទពិសោធន៍ក្នុងវិស័យការងារ
- តាំងបង្ហាញរ៉ូបូតកាហ្វេ ដែលជាស្នាដៃរបស់សិស្ស-និស្សិតសិក្សាជំនាញបច្ចេកទេស និងវិជ្ជាជីវៈ
- តាំងបង្ហាញបញ្ជរផ្តល់សេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិច ដែលបង្កើតឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពង្រីក និងផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់សេវាសាធារណៈរបស់ក្រសួង
- បង្កើតជាវេទិកា តភ្ជាប់បណ្តាញទំនាក់ទំនងក្នុងចំណោម ក្រសួង ស្ថាប័ន និងក្រុមហ៊ុនដែលចូលរួមពិព័រណ៍ការងារ និងផលិតភាពជាតិ។

សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងតាមរយៈ Hotline: ១២៩៧ / ១២៨៦ ឬលេខទូរស័ព្ទ ០៧៧ ២៣២ ៣៧៨/ ០១៧ ៨៧១ ៨០៧។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារ សិស្ស-និស្សិត និងសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៦រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤

www.careerfair.nea.gov.kh